# ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារសំណង សម្រាប់តំបន់ឆ្នេរឈូងសមុទ្រ "GCCF" គោលការណ៍រក្សារឿងផ្ទាល់ខ្លួននៃគេហទំព័រអ៊ីនធើណែត

## I. វិសាលភាព

គោលការណ៍រក្សារឿងផ្ទាល់ខ្លួនរបស់ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារសំណងសម្រាប់តំបន់ឆ្នេរឈូងសមុទ្រ (GCCF)នេះ ត្រូវបានរៀបចំឡើងដើម្បីជម្រាបអ្នកពីទម្លាប់ការអនុវត្តន៏របស់យើងដែលទាក់ទងនឹងការប្រមូលការប្រើប្រាស់ និងការបញ្ចេញព័ត៌មាន ដែលអ្នកប្រហែលនឹងផ្តល់តាមរយៈគេហទំព័រនេះ។ សូមអានគោលការណ៍រក្សារឿងផ្ទាល់ខ្លួនទាំងមូលនេះឲ្យបានច្បាស់មុននឹងបញ្ជូនព័ត៌មានមកគេហទំព័រនេះ។

## II. ការយល់ព្រម

ដោយប្រើគេហទំព័រនេះ អ្នកយល់ព្រមតាមលក្ខខណ្ឌនៃគោលការណ៍រក្សាការរឿងផ្ទាល់ខ្លួននេះ។ នៅពេលណាក៏ដោយ ដែលអ្នកបញ្ជូនព័ត៌មានតាមរយៈគេហទំព័រនេះ គឺអ្នកយល់ស្របនឹងការប្រមូល ការប្រើប្រាស់ និងការបញ្ចេញព័ត៌មាននោះអោយស្របទៅតាមគោលការណ៍រក្សារឿងផ្ទាល់ខ្លួននេះ។ ប្រសិនបើអ្នកមិនចង់បញ្ជូនព័ត៌មានមកយើង តាមរយៈគេហទំព័រអ៊ីនធើណែតនេះទេ សូមអ្នកទាញ់យកនូវទម្រង់ពាក្យប្តឹងទាមទារសំណងពីគេហទំព័រនេះ ហើយបញ្ជូនទម្រង់នោះទៅកាន់អាសយដ្ឋាននៅខាងចុងបញ្ចប់នៃគោលការណ៍រក្សារឿងផ្ទាល់ខ្លួននេះ។

## III. ព័ត៌មានដែលយើងប្រមូលបាន

អ្នកអាចតម្រូវឲ្យផ្តល់នូវព័ត៌មានផ្ទាល់ខ្លួន ដើម្បីចូលទៅកាន់គេហទំព័រអ៊ីនធើណែត។ ដើម្បីប្រើប្រាស់លក្ខណៈពិសេសមួយចំនួនដែលមានលើគេទំព័រ និងដើម្បីអាចឲ្យយើងធ្វើការវាយតម្លៃ និងចាត់ការលើពាក្យបណ្តឹងទារទារសំណងរបស់អ្នក អ្នកប្រហែលត្រូវផ្តល់ព័ត៌មានឲ្យយើងដូចជា៖

- ព័ត៌មានទំនាក់ទំនងរបស់អ្នក (ឈ្មោះ អាសយដ្ឋានអ៊ីមែល អាសយដ្ឋានប្រៃសនីយ៍ លេខទូរស័ព្ទ)
- លេខសុវត្ថិភាពសង្គមប្រចាំខ្លួន ឬលេខអត្តសញ្ញាណពន្ធរបស់អ្នក
- ព័ត៌មានហិរញ្ញវត្ថុរបស់អ្នក
- ព័ត៌មានសុខភាពរបស់អ្នក

## IV. របៀបដែលយើងប្រើប្រាស់ និងចែកចាយព័ត៌មានរបស់អ្នក

យើងប្រើប្រាស់ និងបញ្ចេញព័ត៌មានដែលអ្នកបញ្ជូនមកឲ្យយើង ដោយរាប់បញ្ចូលទាំងព័ត៌មានផ្ទាល់ខ្លួនដើម្បី៖

- រត់ការលើពាក្យបណ្តឹងទារទារសំណង និងប្រាក់សំណងដែលបានមកពីបណ្តឹងទាមទារសំណងនោះ និងទាក់ទងអ្នកពីរឿងពាក្យបណ្តឹងទាមទារសំណង។
- គាំទ្រដល់គោលបំណងអាជីវកម្មស្របច្បាប់របស់ GCCF។
- កំណត់ប្រាក់ដែលបានបង់មកពីការធានារ៉ាប់រង
- ឆ្លើយតបនឹងសំណើផ្នែកអនុវត្តច្បាប់ ឬនៅពេលច្បាប់ចូលជាធរមាន ដីកាតុលាការ ឬបទបញ្ញាត្តិរបស់រដ្ឋាភិបាលតម្រូវអោយមាន។ យើងក៏នឹងត្រូវបញ្ចេញព័ត៌មានដល់អាជ្ញាធរអនុវត្តច្បាប់ណាសមស្រប ប្រសិនបើយើងជឿជាក់ដោយសុចរិតថា ព័ត៌មានដែលបានបញ្ជូនមកឲ្យយើង មានការក្លែងបន្លំ ឬបើគេហទំព័រអ៊ីនធើណែតត្រូវបានប្រើប្រាស់ដោយខុសឆ្គង ក្នុងវិធីមួយដែលអាចរំលោភលើសិទ្ធិ ឬកម្មសិទ្ធិរបស់ GCCF ឬរបស់អ្នកចូលមើលគេហទំព័រអ៊ីនធើណែតផ្សេងៗ ឬជនដទៃទៀត។
- ធ្វើរបាយការណ៍ម្តងម្កាលទៅភាគីពាក់ព័ន្ធ ដោយរាប់បញ្ចូលទាំងក្រុមហ៊ុនរុករក និងផលិតប្រេងប៊ីភី (BP Exploration & Production Inc.) ផង ទាក់ទងនឹងបណ្តឹងទាមទារសំណង និងការកំណត់ពាក្យបណ្តឹងទាមទារសំណង។

យើងប្រហែលនឹងអាចផ្តល់របាយការណ៍ ដែលរាប់បញ្ចូលព័ត៌មានមិនមែនផ្ទាល់ខ្លួនទៅឲ្យមន្ត្រីរដ្ឋាភិបាលសហព័ន្ធ និងតំបន់ក្បែរផ្ទះ និងទៅឲ្យក្រុមហ៊ុនប៊ីភី (BP) ដើម្បីអនុញ្ញាតលើការវាយតម្លៃក្នុងការរត់ការពាក្យបណ្តឹង។

បើអ្នកផ្តល់សេវាកម្មត្រូវបានតម្រូវឲ្យជួយយើងក្នុងសកម្មភាពណាខាងមុខ យើងនឹងតម្រូវឲ្យពួកគេរក្សាព័ត៌មានឲ្យមានសុវត្ថិភាព។ យើងក៏នឹងហាមឃាត់ពួកគេផងដែរ មិនឲ្យប្រើប្រាស់ព័ត៌មានរបស់អ្នកក្នុងគោលបំណងផ្សេងខុសពីគោលបំណងដែលយើងបានស្នើសុំ។ យើងមិនលក់ ឬជួលព័ត៌មានអ្នកទៅឲ្យភាគីទី ៣ ឡើយ។

## V. លទ្ធភាពកែតម្រូវ ឬបញ្ចូលព័ត៌មានថ្មី

ដើម្បីរក្សាព័ត៌មានផ្ទាល់ខ្លួន ដែលអ្នកបានផ្តល់លើគេហទំព័រអ៊ីនធើណែតនេះ ឲ្យបានត្រឹមត្រូវ មានបច្ចុប្បន្នភាព និងពេញលេញ ប្រសិនបើចាំបាច់ សូមអ្នកចូលមកគេទំព័រអ៊ីនធើណែត និងផ្តល់ព័ត៌មានដែលថ្មី ឬបានកែតម្រូវ ហើយយើងនឹងចាត់វិធានការសមស្រប ដើម្បីបញ្ចូលព័ត៌មានថ្មី ឬកែតម្រូវព័ត៌មាននោះ ឲ្យស្ថិតក្នុងការគ្រប់គ្រងរបស់យើង។ លើសពីនេះ អ្នកអាចបញ្ជូនព័ត៌មានថ្មី ឬកែតម្រូវនេះ ទៅកាន់អាសយដ្ឋាន នៅចុងគោលការណ៍រក្សារឿងផ្ទាល់ខ្លួននេះ។

## VI. អំពីកុមារ

គេហទំព័រអ៊ីនធើណែតនេះ មិនមែនរៀបចំឡើងសម្រាប់កុមារអាយុក្រោម១៣ឆ្នាំឡើយ។ យើងគ្មានចេតនានឹងប្រមូលព័ត៌មានផ្ទាល់ខ្លួនលើគេហទំព័រអ៊ិនធឺណេតនេះពីអ្នកចូលមើលដែលស្ថិត រង្វង់អាយុនេះឡើយ។ **ប្រសិនបើអ្នកមានអាយុក្រោម ១៣ ឆ្នាំ សូមកុំប្រើគេហទំព័រអ៊ីនធើណែតនេះ ឬកុំផ្តល់ព័ត៌មានមកឲ្យយើង។** ប្រសិនបើយើងដឹងថា យើងទទួលបាននូវព័ត៌មានផ្ទាល់ខ្លួនពីកុមារអាយុក្រោម ១៣ឆ្នាំ យើងនឹងខិតខំប្រឹងប្រែងឲ្យបានសមរម្យខាងផ្នែកពាណិជ្ជកម្មដើម្បីលុបចោលនូវព័ត៌មានទាំងនេះចេញពីមូលដ្ឋានទិន្នន័យរបស់យើង។

## VII. ព័ត៌មានជាស្ថិតិ

យើងអាចនឹងប្រមូលព័ត៌មានមិនផ្ទាល់ខ្លួនជាស្ថិតិ ស្តីពីការប្រើប្រាស់គេហទំព័រអ៊ីនធើណែត ដូចជាព័ត៌មានថាតើមានមនុស្សប៉ុន្មាននាក់ចូលមើលក្នុងទំព័រអ៊ីនធើណែត ថាតើគេមើលគេហទំព័រនោះបានប៉ុន្មានម៉ោង ចំណុចតភ្ជាប់ទៅទំព័រផ្សេងទៀត ដែលពួកគេបាន"ចុច"។ តាមរយៈការប្រើប្រាស់លក្ខណៈបច្ចេកវិទ្យាផ្សេងៗ ដូចជា "លេខអាយភី" (internet protocol (IP) addresses) (លេខដែលបានកំណត់ដោយស្វ័យប្រវត្តិលើកុំព្យូទ័ររបស់អ្នកនៅពេលអ្នកប្រើអ៊ីនធើណែត) និង "ខូកគី" (cookies) (ព័ត៌មានដែលគេហទំព័រអ៊ីនធើណែតផ្ញើរទៅក្នុងហាដឌ្រាវ (hard drive) ក្នុងគោលបំណងរក្សាទុក) យើងអាចប្រមូលព័ត៌មានប្រភេទនោះ ដើម្បីធ្វើឲ្យគេហទំព័រមានដំណើរត្រឹមត្រូវ ដើម្បីវាយតម្លៃការប្រើគេហទំព័រ និងដើម្បីគាំទ្រដល់វិទ្យាសាស្ត្រវិភាគគេហទំព័រអ៊ិនធឺណេត។ យើងក៏អាចចងក្រងទន្និន័យនោះដើម្បីរៀបរាប់ពីការប្រើគេហទំព័រទៅឲ្យភាគីពាក់ព័ន្ធ ឬឆ្លើយតបទៅនឹងសំណើផ្លូវច្បាប់ និង/ឬរបស់រដ្ឋាភិបាល។ ព័ត៌មានចងក្រងនេះនឹងមិនកំណត់ពីអត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកឬអ្នកចូលមើលដទៃទៀតឡើយ។

## VIII. លេខអាយភី (IP Address)

ម៉ាស៊ីនបំរើ (web server) ជាកុំព្យូទ័រដែល "បង្ហោះ" ទំព័រអ៊ីនធើណែត ដែលកំណត់លេខអាយភីកុំព្យូទ័ររបស់អ្នកដោយស្វ័យប្រវត្តិ។ យើងកត់លេខអាយភីទុកក្នុងគោលបំណងគ្រប់គ្រងប្រព័ន្ធ ដើម្បីរាយការណ៍ពីព័ត៌មានជាស្ថិតិទៅភាគីពាក់ព័ន្ធ និងដើម្បីតាមដានការប្រើប្រាស់គេហទំព័រអ៊ិនធឺណេត។ នៅពេលអ្នកចូលមើលស្នើសុំទំព័រអ៊ិនធឺណេត ពីគេហទំព័រអ៊ិនធឺណេតរបស់យើង ម៉ាស៊ីនបំរើរបស់យើងនឹងកត់លេខអាយភីរបស់អ្នកចូលមើលទុក។ ការតភ្ជាប់លេខអាយភីទៅរកព័ត៌មានផ្ទាល់ខ្លួនមិនមែនជាទម្លាប់អនុវត្តរបស់យើងឡើយ។ ទោះបីការចូលមើលរបស់អ្នកត្រូវបានកត់ត្រាទុកក៏ដោយ ក៏ប៉ុន្តែជាធម្មតា យើងនៅតែមិនស្គាល់អ្នក។ ទោះជាយ៉ាងណា យើងរក្សាសិទ្ធិក្នុងការកំណត់អត្តសញ្ញាណរបស់អ្នក តាមរយៈលេខអាយភី ប្រសិនបើ

យើងជឿជាក់ថា ជាការចាំបាច់ដើម្បីអនុលោមតាមទម្លាប់អនុវត្តផ្នែកព័ត៌មានរបស់គេហទំព័រអ៊ីនធើណែត ឬដើម្បីការពារ GCCF ការពារអ្នកចូលមើលគេហទំព័រអ៊ីនធើណែតដទៃទៀត ឬជនដទៃផ្សេងទៀត។

## IX. សុវត្ថិភាព

ការការពារសុវត្ថិភាពព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជាការសំខាន់ណាស់ចំពោះយើង។ យើងប្រើវិធានការសុវត្ថិភាព ដែលសមស្រប ដែលរៀបចំឡើងដើម្បីការពារការសំងាត់នៃព័ត៌មានផ្ទាល់ខ្លួន។ នៅពេលអ្នកបញ្ជូនព័ត៌មានផ្ទាល់ខ្លួនពីកុំព្យូទ័ររបស់អ្នកមកម៉ាស៊ីនបំរើរបស់យើង ព័ត៌មានរបស់អ្នកត្រូវបានការពារដោយ "ហ្វាយអឺវល" (firewall) (ការរួមផ្សំរវាងហាដវែរ (hardware) និងសូហ្វវែរ (software) ដែលជួយការពារកុំឲ្យអ្នកចូលមើលដែលគ្មានការអនុញ្ញាតិដទៃទៀត ប្រើប្រាស់ព័ត៌មានក្នុងបណ្តាញកុំព្យូទ័ររបស់យើង) ព្រមទាំងដាក់លេខកូដ (Secure Sockets Layer – SSL) ផងដែរ។ នៅពេលយើងទទួលបានព័ត៌មានដែលអ្នកបានបញ្ជូនមក យើងនឹងប្រុងប្រយ័ត្នជាមុនឲ្យបានសមស្រប ក្នុងការរក្សាព័ត៌មានរបស់អ្នកឲ្យមានសុវត្ថិភាពលើបណ្តាញរបស់យើង។ តែទោះយើងខិតខំព្យាយាមការពារការសំងាត់របស់អ្នក គ្មានការបញ្ជូនទិន្នន័យលើប្រព័ន្ធអ៊ិនធឺណេតអាចធានាសុវត្ថិភាពបាន ១០០% ឡើយ។ ដូច្នេះ យើងមិនអាចធានាសុវត្ថិភាពលើព័ត៌មានផ្ទាល់ខ្លួន ដែលបញ្ជូនមកឲ្យយើងតាមប្រព័ន្ធអ៊ីនធើណែតឡើយ ឬលើឯកសារណាមួយដែលអ្នកបង្ហោះលើប្រព័ន្ធអ៊ីនធើណែត ឬមិនអាចទទួលខុសត្រូវចំពោះអំពើចោរកម្ម ការបំផ្លិចបំផ្លាញ ឬការបញ្ចេញដោយអចេតនានូវព័ត៌មាននោះឡើយ។

## X. ការតភ្ជាប់ទៅគេហទំព័រអ៊ីនធើណែតដទៃទៀត

សូមជ្រាបថា នៅពេលអ្នកនៅលើគេហទំព័រអ៊ីនធើណែត អ្នកអាចត្រូវគេបង្វែរទៅរកគេហទំព័រដទៃផ្សេងទៀត ដែលហួសពីការគ្រប់គ្រងរបស់យើង។ ការតភ្ជាប់អាចនាំអ្នកចេញពីទំព័រលើគេហទំព័រអ៊ីនធើណែតនេះទៅកាន់គេហទំព័រអ៊ីនធើណែតដទៃទៀតដែលគ្មានពាក់ព័ន្ធនឹងគេហទំព័រនេះឡើយ។ គេហទំព័រដទៃទៀតទាំងនេះអាចបញ្ជូន "ខូកគី" របស់ខ្លួនទៅអ្នកចូលមើល ប្រមូលទិន្នន័យ ឬសួរយកព័ត៌មានផ្ទាល់ខ្លួន។ គោលការណ៍រក្សាការសំងាត់នៃគេហទំព័រអ៊ីនធើណែតដទៃទៀតទាំងនេះអាចខុសប្លែកខ្លាំងពីគោលការណ៍រក្សាការសំងាត់នេះ។ យើងមិនទទួលខុសត្រូវចំពោះទម្លាប់អនុវត្តរក្សាការសំងាត់របស់គេហទំព័រអ៊ីនធើណែតដទៃទៀតនេះឡើយ ហើយមិនអាចធានាសុវត្ថិភាពលើព័ត៌មានណាមួយ ដែលអាចប្រមូលយកនៅគេហទំព័រទាំងនោះឡើយ។

## XI. ការកែប្រែគោលការណ៍នេះ

ល័ក្ខខ័ណ្ឌនៃគោលការណ៍រក្សារឿងផ្ទាល់ខ្លួននេះអាចផ្លាស់ប្តូរពីពេលមួយទៅពេលមួយទៀត។ ប្រសិនបើមានការកែប្រែ កាលបរិច្ឆេទ "កែប្រែចុងក្រោយ" ("Last Modified" date) នៅផ្នែកខាងលើនៃគោលការណ៍នេះ នឹងកែប្រែថ្មី ដើម្បីឆ្លុះបញ្ចាំងពីការកែប្រែ។ អ្នកអាចត្រូវបានណែនាំ

ឲ្យត្រួតពិនិត្យមើលការកែប្រែជាប្រចាំ។ ការបន្តប្រើប្រាស់គេហទំព័រនេះ បន្ទាប់ពីយើងបង្ហោះការកែប្រែលើគោលការណ៍រក្សាការសំងាត់នេះ នឹងបង្ហាញថាអ្នកទទួលយកនូវការកែប្រែទាំងនោះ។

**XII. សូមទាក់ទងមកយើង/យកឈ្មោះចេញពីបញ្ជីអ៊ីមែល**

ប្រសិនបើអ្នកមានចម្ងល់ យោបល់ សំណើ ឬការព្រួយបារម្ភ ទាក់ទងនឹងគោលការណ៍រក្សារឿងផ្ទាល់ខ្លួននេះ ឬទម្លាប់អនុវត្តផ្នែកព័ត៌មាននៃគេហទំព័រអ៊ីនធើណែតនេះ សូមទាក់ទងយើងតាមរយៈ៖

អ៊ីម៉ែល: info@gccf-claims.com

តាមសំបុត្រ: Gulf Coast Claims Facility
P.O. Box 9658
Dublin, OH 43017-4958

ប្រសិនបើអ្នកមិនចង់ទទួលអ៊ីមែលពីយើងបន្តទៀតនោះ អ្នកអាចដកឈ្មោះចេញបាន ដោយទាក់ទងតាមរយៈ unsubscribe@gccf-claims.com ឬតាមរយៈការបញ្ជូនសំណើជាលាយលក្ខណ៍អក្សរតាមសំបុត្រទៅកាន់អាសយដ្ឋានខាងលើ។